**Royal Commission into Victoria's Mental Health System**

## គណៈកម្មការស៊ើបអង្កេតសាធារណៈជាផ្លូវការ Royal Commission ក្នុងប្រព័ន្ធសុខភាពផ្លូវចិត្តរបស់រដ្ឋវិចថូរៀ

គោលបំណងរបស់គណៈកម្មការស៊ើបអង្កេតសាធារណៈជាផ្លូវការ Royal Commission គឺដើម្បីផ្តល់នូវសកម្មភាពច្បាស់លាស់ដែលនឹងផ្លាស់ប្តូរប្រព័ន្ធសុខភាពផ្លូវចិត្តរបស់រដ្ឋវិចថូរៀ និងដើម្បីជួយឱ្យពលរដ្ឋវិចថូរៀទទួលបាននូវបទពិសោធន៍សុខភាពផ្លូវចិត្តល្អប្រសើរបំផុត។

ដើម្បីអភិវឌ្ឍការរកឃើញ និងអនុសាសន៍របស់យើង យើងកំពុងទាក់ទិនជាមួយសហគមន៍វិចថូរៀ ហើយយើងខ្ញុំកំពុងស្នើសុំលោកអ្នកឱ្យចែករំលែក បទពិសោធន៍ ទស្សនៈ និងគំនិតរបស់លោកអ្នក ដើម្បីជួយកែលម្អប្រព័ន្ធសុខភាពផ្លូវចិត្តរបស់យើង។

យើងមានទំនាក់ទំនងតាមអ៊ីនធើណិត ដែលអនុញ្ញាតឱ្យលោកអ្នកចែករំលែកការរួមចំណែករបស់លោកអ្នកជាការដាក់ស្នើអត្ថបទលាយលក្ខណ៍អក្សរ រូបភាព វីដេអូ ឬសម្លេង។ សំណុំបែបបទនេះមាននៅក្នុងភាសាខុសៗគ្នាជាច្រើន។

ការផ្តោតអារម្មណ៍របស់គណៈកម្មការគឺលើការកំណត់ និងដោះស្រាយបញ្ហាប្រព័ន្ធទាំងមូល ជាជាងការស៊ើបអង្កេតករណីបុគ្គល ឬឧប្បត្តិហេតុនានា។

លោកអ្នកអាចធ្វើការរួមចំណែករបស់លោកអ្នកដោយ៖

- ហៅទូរស័ព្ទលេខ **1800 00 11 34** ឬ **03 7005 3010** ប្រសិនបើលោកអ្នកត្រូវការសេវាកម្មអ្នកបកប្រែភាសា ( ដែលអាចប្រើបានចាប់ពីម៉ោង៩ព្រឹក - ៥ល្ងាច ពីថ្ងៃច័ន្ទ ទៅថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកសាធារណៈ)
- ការសរសេរទៅ៖ PO Box 12079, A'Beckett St, Victoria 8006 ( យើងនឹងបកប្រែលិខិតរបស់លោកអ្នក)
- បំពេញ ហើយដាក់ការស្នើសុំតាមអនឡាញនៅត្រង់៖ https://rcvmhs.vic.gov.au/submissions
- អ៊ីម៉េល៖ contact@rcvmhs.vic.gov.au

## ប្រសិនបើលោកអ្នកមានកង្វល់បច្ចុប្បន្ន អំពីអ្នកផ្តល់សេវាកម្មសុខភាពផ្លូវចិត្តណាមួយ

គោលបំណងរបស់គណៈកម្មការស៊ើបអង្កេតសាធារណៈជាផ្លូវការ Royal Commission មិនអាចដោះស្រាយបណ្តឹងតវ៉ា ឬវិវាទបុគ្គលឡើយ។ ប្រសិនបើលោកអ្នកមានកង្វល់អំពីបទពិសោធន៍របស់លោកអ្នក ជាមួយសេវាកម្មសុខភាពផ្លូវចិត្តសាធារណៈរបស់រដ្ឋវិចថូរៀ លោកអ្នកអាចទាក់ទងមកសេវាកម្មដោយផ្ទាល់ ឬនិយាយជាមួយស្នងការដោះស្រាយបណ្តឹងសុខភាពផ្លូវចិត្ត (MHCC) ។

MHCC គឺជាស្ថាប័នឯករាជ្យឯកទេសមួយដែលការពារសិទ្ធិ និងដោះស្រាយបញ្ហាអំពីសេវាកម្មសុខភាពផ្លូវចិត្តសាធារណៈ។ លោកអ្នកអាចទាក់ទងមក MHCC តាមទូរស័ព្ទលេខ 1800 246 054 ឬអ៊ីម៉េល help@mhcc.vic.gov.au ។ លោកអ្នកក៏អាចចូលមើលផងដែរនៅតាមវ៉ិបសៃថ៍ www.mhcc.vic.gov.au សម្រាប់ព័ត៌មានបន្ថែម។

## ប្រសិនបើលោកអ្នកមានកង្វល់ អំពីអ្នកប្រតិបត្តិផ្នែកសុខភាពដែលបានចុះបញ្ជីស្របច្បាប់ណាមួយ

ប្រសិនបើកង្វល់របស់លោកអ្នកគឺអំពីការប្រព្រឹត្ត ឬការអនុវត្តរបស់អ្នកប្រតិបត្តិផ្នែកសុខភាពដែលបានចុះបញ្ជីស្របច្បាប់ណាមួយ ( ដូចជាវេជ្ជបណ្ឌិតវិកលចរិត អ្នកចិត្តសាស្ត្រ វេជ្ជបណ្ឌិតដែលបានចុះបញ្ជីស្របច្បាប់ជាដើម) លោកអ្នកអាចទាក់ទងមកភ្នាក់ងារនិយតកម្មអ្នកប្រតិបត្តិសុខភាពរបស់ប្រទេសអូស្ត្រាលី (AHPRA) ។ លោកអ្នកអាចទាក់ទង AHPRA ដោយហៅទូរស័ព្ទលេខ 1300 419 495 ឬបើកមើលនៅតាមវ៉ិបសៃថ៍ www.ahpra.gov.au ។

## ប្រសិនបើលោកអ្នកមានកង្វល់អំពីសេវាកម្មសុខភាពឯទៀត

ស្នងការដោះស្រាយបណ្តឹងផ្នែកសុខភាព (HCC) គឺជាស្ថាប័នឯករាជ្យ ហើយមិនលំអៀង សម្រាប់ពាក្យបណ្តឹងអំពីសេវាកម្មសុខភាព និងបញ្ហាសុខភាពក្នុងរដ្ឋវិចថូរៀ។ HCC អាចទទួលពាក្យបណ្តឹងអំពីសេវាកម្មសុខភាពផ្លូវចិត្តឯកជន ឬអ្នកផ្តល់សេវាកម្មនានា។ លោកអ្នកអាចទាក់ទងមក HCC ដោយទូរស័ព្ទលេខ 1300 582 113 ឬបើកមើលនៅតាមវ៉ិបសៃថ៍ www.hcc.vic.gov.au ។